00229467

D55/I/9

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ : 002/19-09-2007-អវតក/កសចស(អបជ០៦)

ដាក់ជូន : អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ជូន : ១៣ តុលា ២០០៨

ភាគីដាក់ឯកសារ : សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ភាសាដើម : អង់គ្លេស

ប្រភេទឯកសារ : សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 10 / 2008
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

**សំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញលើការខាយតម្លៃរបស់អង្គបុរេជំនុំជម្រះលើឋានានុក្រមគតិយុត្តិនៃវិធានផ្ទៃក្នុងក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ជំទាស់នឹងដីកាបដិសេធសំណើសុំអោយគាត**

---

**<u>ដាក់ជូនដោយ:</u>**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោកស្រីSilk STUDZINSKY

លោក គឹម ម៉េងឃី

លោក Martine JAQUIN

លោក Philippe CANNONE

**<u>ដាក់ជូន</u>**

**អង្គបុរេជំនុំជម្រះ**

ចៅក្រមប្រាក់ គឹមសាន

ចៅក្រមហួត វុទ្ធី

ចៅក្រមRowan DOWNING

ចៅក្រមន័យ ធុល

ចៅក្រមKatinka LAHUIS

**សហមេធាវីការពារក្តី**

លោក សុន អារុណ

លោក Michiel PESTMAN

លោក Victor KOPPE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

00229468

D55/I/9

## ១. សាវតានីតិវិធី

១. ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ មេធាវីរបស់ នួន ជា បានដាក់បណ្ដឹងឧទ្ធរណ៍ "ឧទ្ធរណ៍"[1] ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស")។ ក្នុងរឿងនោះ មេធាវីបានលើកឡើងចំនុចជាច្រើន ដែលក្នុងនោះមេធាវីបានបញ្ជាក់ថា ច្បាប់កម្ពុជា មានជាអាទិ៍ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា("កនព") មានអាទិភាពក្នុងករណីមានភាពមិនស្របគ្នា[2]។

២. ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ("អបជ") បានសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះ ("សេចក្ដីសម្រេច") និងបានលើកឡើងអំពីទំនាក់ទំនងរវាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង ដែលវិធានផ្ទៃក្នុងជាលិខិតតុបករណ៍គោលនៅក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងលើកឡើងថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអនុវត្តតែនៅក្នុងករណីដែលវិធានផ្ទៃក្នុងមិនមានចែងចំពោះបញ្ហានោះ[3]។

## ២. សេចក្ដីសង្ខេបអំពីឧទ្ធរណ៍

៣. កិច្ចប្រជុំពេញអង្គមិនមានអំណាចអនុម័តវិធានផ្ទៃក្នុង ដែលមានតម្លៃស្មើនឹងច្បាប់នីតិវិធីពេញលេញដោយខ្លួនឯងនោះទេ។ មានតែសភាជាតិប៉ុណ្ណោះ ដែលមានអំណាចនីតិបញ្ញត្តិ។ ទាំងកិច្ចព្រមព្រៀងស្ដីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទាំងច្បាប់ស្ដីពី

---

[1] ករណី នួន ជា បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ D55/I/1, ERN 00165047-00165056

[2] ឯកសារដដែល កថាខណ្ឌ១២

[3] ករណី នួន ជា សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់នួន ជា ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ D55/I/8, ERN 00219322-00219333 កថាខណ្ឌ១៤ កថាខណ្ឌ១៥

ការបង្កើតអ.វ.ត.ក មិនផ្តល់អំណាចធ្វើច្បាប់បែបនេះដល់កិច្ចប្រជុំពេញអង្គទេ។ ដូចគ្នានេះដែរ អំណាចរបស់ចៅក្រម អ.វ.ត.ក ដើម្បីធ្វើវិសោធនកម្មផ្នែកសំខាន់នៃវិធានផ្ទៃក្នុង គឺមិនអនុលោមទៅតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទេ។

៤. បើទោះបីជា វិធានផ្ទៃក្នុងមានសុពលភាពក៏ដោយ ក៏វិធានទាំងនេះស្ថិតនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាតាមគោលការណ៍ដែលច្បាប់កំពូល (Lex superior) សំខាន់ជាងច្បាប់ទាប (Lex inferior)។ ដូច្នេះសំណើសុំឱ្យធ្វើការពិចារណាឡើងវិញត្រូវតែទទួលយក ពីព្រោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចមោឃភាពលើករណី នួន ជា គឺភាន់ច្រឡំ និងមិនយុត្តិធម៌សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

## ៣.កំណត់សម្គាល់បឋម

### ក. ភាពអាចទទួលយកបាននៃសំណើសុំ

៥. សិទ្ធិស្នើសុំការពិចារណាឡើងវិញលើសេចក្តីសម្រេចណាមួយ ឬផ្នែកណាមួយនៃសេចក្តីសម្រេចនោះត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ[4]។ អង្គបុរេជំនុំជម្រះយល់ស្របតាមសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ("ICTY") ដូច្នេះហើយសន្និដ្ឋានថាសំណើសុំការពិចារណាឡើងវិញនេះ គឺជាឱកាសតែមួយដើម្បីបដិសេធសេចក្តីសម្រេចជាពិសេសចំពោះសេចក្តីសម្រេចចុងក្រោយបំផុតរបស់តុលាការ។

សំណើសុំបែបនេះនឹងត្រូវទទួល:

(i) នៅពេលដែលកាលៈទេសៈបានប្រែប្រួល ហើយអង្គហេតុថ្មី ឬទឡ្ហីករណ៍ថ្មីៗបានលេចឡើង ឬ

[4] ករណី អៀង សារី **សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញអំពីសិទ្ធដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យដោយផ្ទាល់ទៅអង្គបុរេជំនុំជម្រះ** ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ C22/I/68, ERN 00221475-00221484 កថាខណ្ឌ២៥

(ii) នៅពេលដែលគេដឹងថា សេចក្ដីសម្រេចពីមុនមានការភាន់ច្រឡំ ឬ

(iii) នៅពេលដែលសេចក្ដីសម្រេចពីមុនបានបណ្ដាលឱ្យមានភាពអយុត្តិធម៌។

៦. ដូចគ្នានេះដែរ សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") ក៏បានកត់សម្គាល់ដែរថា[5] "......... *អង្គជំនុំជម្រះសាលាឧទ្ធរណ៍មានឆន្ទានុសិទ្ធិពេញលេញក្នុងការពិចារណាឡើងវិញអំពីសេចក្ដីសម្រេចរបស់ខ្លួនពីមុនមក លើកលែងតែសម្រេចចុងក្រោយ បើសិនជាការកើតមានកំហុសច្បាស់លាស់ត្រូវបានបង្ហាញ ឬបើសិនជាការចាំបាច់ក្នុងការការពារកុំឱ្យមានភាពអយុត្តិធម៌។*"

៧. គោលការណ៍ទូទៅនេះ ដែលគ្រប់តុលាការអាចកែប្រែ ឬទុកជាមោឃៈដីកាពីមុន ក៏ត្រូវបានទទួលស្គាល់ដោយតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ("SCSL")[6] ដែរ។

៨. ដោយពិចារណាអំពីគោលការណ៍ទាំងអស់នេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមលើកឡើងថា ការពិចារណាឡើងវិញគឺជាចំណាត់ការដ៏សមស្រប និងចាំបាច់បំផុតចំពោះសំណើនេះ ដោយហេតុថា:

(i) ភាគីមួយមិនបានដាក់សារណាតបលើខ្លឹមសារនៃបណ្ដឹងឧទ្ធរណ៍

(ii) សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះជះឥទ្ធិពលយ៉ាងខ្លាំងលើ សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងបង្ហាញឱ្យឃើញពីចំណាត់ការជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីទាំងមូលជាពិសេសគឺការបកស្រាយទំនាក់ទំនងជាទូទៅរវាងវិធានផ្ទៃក្នុង ("IR") និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា("CPC")។

---

[5] ព្រះរាជអាជ្ញា *ទល់នឹង* Aloys Simba ICTR-01-76-A **សេចក្ដីសម្រេចស្ដីលើសំណើរបស់ភាគីប្ដឹងឧទ្ធរណ៍សុំការពិចារណាឡើងវិញលើដីកាពាក់ព័ន្ធនឹង Aloys Simba** សារណារបស់ភាគីប្ដឹងឧទ្ធរណ៍ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦។

[6] ព្រះរាជអាជ្ញា *ទល់នឹង* Norman និងអ្នកផ្សេងទៀត SCSL-04-14-T-507 **សេចក្ដីសម្រេចលើសំណើបន្ទាន់សុំការពិចារណាឡើងវិញស្ដីអំពីការត្រៀមខ្លួន និងការបង្ហាញអំពីសំណុំរឿងរបស់ចុងចោទ** ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ៩ *ដល់*កថាខណ្ឌ១៤

## ខ. វិសាលភាពនៃសំណើសុំការពិចារណាឡើងវិញ

៩. សំណើសុំនេះធ្វើឡើងតែចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលទាក់ទងទៅនឹង:

(i) ការចាត់ទុកវិធានផ្ទៃក្នុងជាច្បាប់នីតិវិធី

(ii) ទំនាក់ទំនងវិធានផ្ទៃក្នុងជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង

(iii) សេចក្តីសន្និដ្ឋានថា វិធានផ្ទៃក្នុងជាលិខិតតុបករណ៍គោល ក្នុងករណីមានភាពខុសគ្នារវាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង។

សហមេធាវីមិនស្នើសុំឲ្យអង្គបុរេជំនុំជម្រះពិចារណាលើសេចក្តីសម្រេចទាំងមូលឡើងវិញទេ។

១០. សំណើសុំការពិចារណាឡើងវិញនេះ គឺយោងដោយផ្ទាល់ទៅលើការអះអាងខាងក្រោមរបស់អង្គបុរេជំនុំជម្រះ:

"វិធានផ្ទៃក្នុងបង្កើតបានជាច្បាប់នីតិវិធីដែលគ្រប់គ្រាន់ពេញលេញដោយខ្លួនឯង ឆ្លើយតបទៅនឹងលក្ខណៈពិសេសរបស់អ.វ.ត.ក ដែលវិធានទាំងនេះបានធ្វើឡើងនិងអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក។ វិធានទាំងនេះមិនធ្វើឡើងឲ្យផ្ទុយទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ តែបេសកកម្មរបស់ អ.វ.ត.ក មានលក្ខណៈពិសេសខុសឆ្ងាយពីការប្រតិបត្តិជាធម្មតារបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឲ្យមានប្រព័ន្ធអនុវត្តជាពិសេសនេះ។ ហេតុដូច្នេះហើយ វិធានផ្ទៃក្នុងចាត់ទុកថាជាច្បាប់បឋម ដែលត្រូវយោងទៅរក ដើម្បីកំណត់កិច្ចដំណើរការនីតិវិធីនៅចំពោះ មុខ អ.វ.ត.ក នៅពេលដែលមានភាពខុសគ្នារវាងនីតិវិធីនៅក្នុងវិធានផ្ទៃក្នុង និង នីតិវិធីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ *បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុវត្តតែនៅពេលដែលមានចំណោទបញ្ហាមួយកើតមានឡើង ហើយមិនមានចែងក្នុងវិធានផ្ទៃក្នុងតែប៉ុណ្ណោះ*[7]។"

[7] សូមអានកំណត់ជើងទំព័រ ៣ (មានសេចក្តីបញ្ជាក់បន្ថែម)

## គ. ឥទ្ធិពលនៃការអះអាងរបស់អង្គបុរេជំនុំជម្រះទៅលើដើមបណ្តឹងរដ្ឋប្បវេណី

១១. វិធានផ្ទៃក្នុងខុសពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានៅក្នុងបញ្ញត្តិជាច្រើន។ ដូច្នេះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនឹងជះឥទ្ធិពលយ៉ាងពិតប្រាកដលើដើមបណ្តឹងរដ្ឋប្បវេណី។ ភាពខុសគ្នារវាងបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងអាចដោយសារតែហេតុថា នៅពេលវិធានផ្ទៃក្នុងត្រូវបានអនុម័ត (ខែមិថុនា ឆ្នាំ២០០៧ ) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនទាន់ចូលជាធរមាននៅឡើយ(ខែសីហា ឆ្នាំ២០០៧)។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមិនខុសគ្នាប៉ុន្មានពីច្បាប់ដែលត្រូវបានអនុម័តក្រោយមកនោះគឺមានរួចទៅហើយនៅពេលនោះ ឯសភាជាតិក៏បានអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអំឡុងសម័យប្រជុំពេញអង្គពេលនោះផងដែរ។ ដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះយល់ឃើញថា ភាពខុសគ្នារវាងកិច្ចដំណើការនីតិវិធីធម្មតារបស់តុលាការកម្ពុជា និងកិច្ចដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក តម្រូវឱ្យមានវិធានជាពិសេសជាក់លាក់។ ដូច្នេះភាពខុសគ្នាពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានយុត្តិកម្មគ្រប់គ្រាន់ ក្នុងន័យថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានេះត្រូវយកមកអនុវត្ត តែក្នុងករណីដែលមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងប៉ុណ្ណោះ។

ដូច្នេះគេអាចសន្និដ្ឋានបានថា ភាពខុសគ្នារវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបានដឹងជាមុន និងបានធ្វើឡើងដោយចេតនា។ អ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងពិតជាបានដឹងអំពីបទបញ្ញត្តិនៃសេចក្តីព្រាងនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

១២. វិធានផ្ទៃក្នុងបានកំហិតសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងស្ថានភាពជាច្រើន ដែលស្ថានភាពទាំងនេះមានចែងរួចទៅហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ឧទាហរណ៍:

(i) តាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបានរហូតដល់ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ[8]។ ទោះជាយ៉ាងនេះក្តី វិធាន២៣(៤) កំណត់កាលបរិច្ឆេទចំនួន១០ថ្ងៃ មុនការបើកសវនាការបឋម។

[8] សូមអានមាត្រា៣១១(២) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

(ii) ក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ[9]។តាមវិធាន៧៤(៤) ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយបានទេ។

## ៤. បទប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធ

១៣. កិច្ចព្រមព្រៀង[10]រវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាដែលទាក់ទងទៅនឹងការចោទប្រកាន់តាមច្បាប់កម្ពុជា[11] អំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តអំឡុងកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")ចែងនៅក្នុងមាត្រា២ (២):

"កិច្ចព្រមព្រៀងនេះអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅពេលអនុម័ត និងធ្វើវិសោធនកម្មរួច។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសមាត្រា២៦ និង២៧"។

១៤. មាត្រា១២ (១) នៃកិច្ចព្រមព្រៀងចែងថា:

"នីតិវិធីត្រូវស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

[9] សូមអានមាត្រា២៦៨(៩) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[10] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាដែលទាក់ទងទៅនឹងការចោទប្រកាន់តាមច្បាប់កម្ពុជា អំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តអំឡុងកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤

[11] មានសេចក្តីបញ្ជាក់បន្ថែម

១៥. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("ច្បាប់ អ.វ.ត.ក")[12] ចែងនៅក្នុងមាត្រា៣៣ (ថ្មី) (១):[13]

"អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធីដែលមានស្រាប់នោះ ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពស្របគ្នានៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

១៦. តាមរដ្ឋធម្មនុញ្ញ រដ្ឋសភា និងព្រឹទ្ធសភា គឺជាអង្គនីតិបញ្ញត្តិ។ មាត្រា៩០(ថ្មី)(១) ចែងថា:

"សភាជាតិជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ។ អំណាចនេះមិនអាចផ្ទេរទៅអង្គការណាផ្សេង ឬបុគ្គលណាទេ"។

១៧. បុព្វកថាវិធានផ្ទៃក្នុង[14]លើកឡើងនៅក្នុងកថាខណ្ឌចុងក្រោយថា:

" អាស្រ័យហេតុនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តវិធានផ្ទៃក្នុង ដូចខាងក្រោម ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជាសម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងដោយអនុលោមតាមមាត្រា២០ថ្មី ២៣ថ្មី និងមាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា១២-១ នៃកិច្ចព្រមព្រៀង អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹង

[12] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសបទឧក្រិដ្ឋដែលបានប្រព្រឹត្ត អំឡុងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចុះហត្ថលេខា ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ បន្ថែមវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ តុលា ឆ្នាំ២០០៤ (NS/RKM/1004/006)

[13] សូមអានមាត្រា២០ (ថ្មី) សម្រាប់សហព្រះរាជអាជ្ញា និងមាត្រា២៣ (ថ្មី) សម្រាប់សហចៅក្រមស៊ើបអង្កេត

[14] វិធានផ្ទៃក្នុង (Rev២) ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧

ការបកស្រាយ ឬការអនុវត្តន៍ ឬប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពស្របគ្នារវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ។"

១៨. តាមការប្រៀបធៀប កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងប្រទេសសេរ៉ាឡេអូន ចែងនៅក្នុងមាត្រា១ដូចខាងក្រោម:

ការបង្កើតតុលាការពិសេស

១. [...]

២. តុលាការពិសេសត្រូវប្រព្រឹត្តទៅស្របតាមលក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។ លក្ខន្តិកៈនេះត្រូវបានភ្ជាប់មកជាមួយជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ហើយបង្កើតបានជាលិខិតុបករណ៍សំខាន់មួយនៃកិច្ចព្រមព្រៀងនេះ។

១៩. លក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("SCSL")ចែងនៅក្នុងមាត្រា១៤ថា:

វិធាននីតិវិធី និងភស្តុតាង

១. វិធាននីតិវិធីនិងភស្តុតាងដែលកំពុងអនុវត្តនៅក្នុងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា នៅពេលតុលាការពិសេសនេះត្រូវបានបង្កើតឡើងអាចអនុវត្តបាន *បើមានការចាំបាច់* ដើម្បីដឹកនាំកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការពិសេសនេះ។

២. ចៅក្រមតុលាការពិសេសរួមគ្នា អាចធ្វើវិសោធនកម្មវិធាននីតិវិធី និងភស្តុតាង ឬអនុម័តវិធានបន្ថែម នៅពេលណាដែលវិធានជាធរមានមិនមាន ឬមិនគ្រប់គ្រាន់សម្រាប់ស្ថានភាពពិសេសណាមួយ។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ចៅក្រមអាចស្វែងរកការណែនាំ តាមការសមស្រប ពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៦៥ របស់សេរ៉ាឡេអូន។

២០. សារសំខាន់នៃបទប្បញ្ញត្តិទាំងនេះនៃច្បាប់កម្ពុជា ក៏ដូចជាការប្រៀបធៀបយ៉ាងល្អនៃលក្ខន្តិកៈតុលាការពិសេសសម្រាប់សេរ៉ាឡេអូននឹងត្រូវលើកយកមកពិភាក្សាដូចខាងក្រោម។

## ៥. ឧទ្ទិសករណ៍

### ក. សិទ្ធិអំណាចរបស់កិច្ចប្រជុំពេញអង្គក្នុងការអនុម័តវិធានផ្ទៃក្នុង

២១. វិធានផ្ទៃក្នុងដំបូងត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គរបស់អ.វ.ត.ក នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧។ យោងតាមវិធាន១៨ សហចៅក្រមស៊ើបអង្កេត ចៅក្រមអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា ប្រធានផ្នែកគាំពារការការពារក្តី ប្រធានអង្គភាពជនរងគ្រោះ ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលអាចចូលរួមក្នុងកិច្ចប្រជុំពេញអង្គបាន។

កិច្ចប្រជុំពេញអង្គមិនធ្វើជាសាធារណៈទេ។ យោងតាមវិធាន១៨(៣)(ខ)មានតែសហចៅក្រមស៊ើបអង្កេត ចៅក្រមអង្គជំនុំជម្រះប៉ុណ្ណោះ ដែលមានសិទ្ធិបោះឆ្នោតអនុម័តវិធាននានាក្នុងជំពូកទី៣ នៃវិធានផ្ទៃក្នុង ពោលគឺចាប់ពីវិធាន២១ ដល់វិធាន១១៤ ដែលជាផ្នែកសំខាន់នៃវិធានផ្ទៃក្នុង។
ភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធីមិនត្រូវបានអនុញ្ញាតឱ្យចូលរួម ឬផ្តល់យោបល់ផ្ទាល់ខ្លួនដើម្បីធ្វើវិសោធនកម្មទេ។

២២. រដ្ឋធម្មនុញ្ញកម្ពុជា[15]ចែងអំពីការបង្កើតប្រព័ន្ធលិទ្ធិប្រជាធិបតេយ្យសេរី និងរចនាសម្ព័ន្ធដឹកនាំតាមគោលការណ៍បែងចែកអំណាចដាច់ពីគ្នារវាង អង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ និងតុលាការ។ ដូច្នេះ តាមរដ្ឋធម្មនុញ្ញកម្ពុជាអំណាចទាំងបីនេះត្រូវបានបែងចែកដាច់ពីគ្នា។

២៣. ការអះអាងយ៉ាងច្បាស់ក្នុងច្បាប់រដ្ឋធម្មនុញ្ញ នៃការបែងចែកដាច់ពីគ្នារវាងអំណាចទាំងបីនេះបញ្ជាក់ច្បាស់ថាគ្មានស្ថាប័នណា ឬបុគ្គលណាផ្សេងអាចមានសិទ្ធិតាក់តែងច្បាប់ឡើយ[16]។

---

[15] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចងក្រង និងបោះពុម្ពផ្សាយជាភាសាអង់គ្លេស និងបារាំងដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៨

[16] សូមមើលមាត្រា៩០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទោះបីជាយ៉ាងដូច្នេះក្តី ក៏អាចមានការផ្ទេរអំណាចទៅរដ្ឋមន្ត្រីណាម្នាក់ ឬសមត្ថកិច្ចរដ្ឋាភិបាលណាមួយ ឱ្យធ្វើជាអ្នកតាក់តែងមាត្រានានាក្រោមច្បាប់ដែលសភាជាតិត្រូវអនុម័តផងដែរ។ ក៏ប៉ុន្តែក្នុងគ្រប់ករណីទាំងអស់ វាមានការចាំបាច់ដែលតម្រូវឱ្យវិធានទាំងនោះ ត្រូវបានសភាជាតិជាអ្នកអនុម័តដោយផ្ទាល់តែម្តង។ ហេតុដូច្នេះ មាត្រាណាមួយ វិធានណាមួយដែលតាក់តែង ឬបង្កើតឡើងដោយរដ្ឋាភិបាល ឬស្ថាប័នណាមួយ តែមិនត្រូវបានសភាជាតិអនុម័តនោះ នឹងត្រូវបានចាត់ទុកថាអធម្មនុញ្ញភាព។ សិទ្ធិអំណាចក្នុងការតាក់តែងវិធាន តាមរយៈការធ្វើប្រតិភូកម្ម ត្រូវប្រើប្រាស់ដោយអនុលោមយ៉ាងតឹងរ៉ឹងតាមច្បាប់ដែលសភាជាតិបានអនុម័ត ឬបើមិនដូច្នោះទេ ត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ។

២៤. វិធានផ្ទៃក្នុងមិនត្រូវបានសភាជាតិអនុម័ត រីឯសិទ្ធិក្នុងការតាក់តែងវិធានវិញ ក៏មិនត្រូវបានប្រគល់ទៅឱ្យកិច្ចប្រជុំពេញអង្គដែរ។ បន្ថែមពីលើចំណុចនេះ យើងអាចទាញការសន្និដ្ឋានបានថា ក្រោមគោលការណ៍បែងចែកអំណាចដែលកំពុងអនុវត្តសព្វថ្ងៃ ក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់មិនបានអនុញ្ញាតឱ្យចៅក្រមធ្វើការអនុម័តវិធាននីតិវិធីណាមួយទេ។

២៥. ការរិះគន់ពីអ្នកស្រាវជ្រាវថ្មីៗនេះ បានលើកហេតុផលថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ រដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជា ជាទូទៅមិនបានផ្តល់សិទ្ធិអំណាចដល់សម័យប្រជុំពេញអង្គ ក្នុងការអនុម័តវិធាន និងធ្វើវិសោធនកម្មវិធានទាំងអស់នោះទេ[17]។

២៦. ទម្លាប់អនុវត្តន៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានចៅក្រមជាអ្នកអនុម័ត និងធ្វើវិសោធនកម្មវិធាននៃនីតិវិធីនានាកន្លងមកនោះ គឺមិនអាចផ្ទេរ ឬយកជា

[17] សូមមើល Guido Acquaviva, New Paths in International Justice? 6 J. Int'l Crim. Just. 129. ទំព័រ ១៣២។

យុត្តិសាស្ត្រសម្រាប់អនុវត្តនៅអ.វ.ត.កបានទេ។ សាលាក្ដី ដែលបានលើកឡើងខាងលើ មិនដូចសាលាក្ដីខ្មែរក្រហមក្នុប្រវត្តកកើតរបស់ខ្លួន ហើយលើសពីនេះទៅទៀត តុលាការអន្តរជាតិទាំងនេះ ក៏មិនបានយកច្បាប់ជាតិមកប្រើ ឬត្រូវដឹកនាំកិច្ចដំណើការនីតិវិធីតាមប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌជាតិ ដូចសាលាក្ដីខ្មែរក្រហមដែរ។

២៧. ក្នុងករណីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនវិញ ដែលគេធ្វើអ្វីៗផ្អែកតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូនបានផ្ដល់នូវសិទ្ធិយ៉ាងជាក់លាក់ថា ក្នុង កាលៈទេសៈពិសេសណាមួយ ចៅក្រមអាចអនុម័ត និងធ្វើវិសោធនកម្មវិធាននីតិវិធី និងភស្តុតាងបាន[18]។

២៨. ហេតុដូច្នេះ សហមេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា កិច្ចប្រជុំពេញអង្គពិតជាពុំមានសិទ្ធិអំណាចអនុម័តវិធាននីតិវិធី ដូចដែលមានចែងក្នុងវិធាន១៨ នៃវិធានផ្ទៃក្នុង ដែលផ្ទុយពីបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមានក្នុងពេលបច្ចុប្បន្ន។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមទទូចលើកឡើងថា វិធានដែលបានប្រកាសឲ្យប្រើដោយរដ្ឋធម្មនុញ្ញភាព ហើយក៏គ្មានការធ្វើប្រតិភូកម្មអំណាចធ្វើច្បាប់ណាមួយដល់ចៅក្រមទៀតនោះ ធ្វើឲ្យវិធានទាំងនេះមិនអាចចាត់ទុកថាជា[19] វិធានដែលមានគ្រប់គ្រាន់ពេញលេញជាច្បាប់នីតិវិធីឡើយ។
វិធានទាំងនោះ មិនមានបុគ្គលិកលក្ខណៈគតិយុត្តិស្មើនឹង"ច្បាប់នីតិវិធី"បានទេ ហើយក៏មិនអាចចាត់ទុកថាមាន លក្ខណៈស្មើភាពជាមួយច្បាប់កម្ពុជា ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសុពលភាពតាមច្បាប់រដ្ឋធម្មនុញ្ញជាដើម។

**ខ. វិសាលភាព និងដែនកំណត់នៃវិធានផ្ទៃក្នុង ព្រមទាំងទំនាក់ទំនងវិធានផ្ទៃក្នុងជាមួយក្រមនីតិវិធីព្រហ្មទណ្ឌ និងទំនាស់/ភាពខុសគ្នា រវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ**

---

[18] សូមមើលមាត្រា១៤ នៃច្បាប់លក្ខន្តិកៈ។

[19] សូមមើល កំណត់ជើងទំព័រ ៣។

២៩. បើទោះជាការអនុម័តវិធាននៃផ្ទៃក្នុងអនុលោមទៅតាមច្បាប់នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ហើយវិធានទាំងនេះមានសុពលភាពអនុវត្តក្តី ក៏ឋានានុក្រមនៃវិធានផ្ទៃក្នុងក្នុងឋានានុក្រមនៃច្បាប់កម្ពុជា មានកម្រិតត្រឹមតែជាវិធានសម្រាប់អនុវត្តមួយផ្នែកប៉ុណ្ណោះ។

៣០. ចំណងជើងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[20] បានបង្ហាញយ៉ាងច្បាស់ថា ការកាត់សេចក្តីបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងធ្វើឡើង *ក្រោមច្បាប់កម្ពុជា*។

លើសពីនេះ មាត្រា១២ នៃកិច្ចព្រមព្រៀងបានបញ្ជាក់យ៉ាងច្បាស់ថា "នីតិវិធីត្រូវអនុលោមទៅតាមច្បាប់កម្ពុជា"។

ដូចគ្នានេះ មាត្រា២០ (ថ្មី) ២៣ (ថ្មី) ៣៣ (ថ្មី) នៃច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថាទាំងសហព្រះរាជអាជ្ញា ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះផងត្រូវដោះស្រាយបញ្ហា "...អនុលោមទៅតាមនីតិវិធីដែលមានស្រាប់"។

៣១. កិច្ចព្រមព្រៀងបញ្ជាក់យ៉ាងច្បាស់ក្នុងមាត្រា២ និង៣១ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាមានអាទិភាពជាងច្បាប់ដែលតាក់តែងឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[21]។ ឧទាហរណ៍ វិសោធនកម្មណាមួយទៅលើច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "... ត្រូវប្រព្រឹត្តទៅដោយមានការពិភាក្សាពិគ្រោះយោបល់រវាងភាគីទាំងអស់" ជាដើម។

---

[20] "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែល ប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" (បញ្ជាក់បន្ថែម)។ លើសពីនេះ យោងតាមមាត្រា៣១ (១) នៃកិច្ចព្រមព្រៀង វាត្រូវយកមកអនុវត្តដូចច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែរ។

[21] សូមមើល Ernestine E. Meijer in: Cesare P.R. Romano, André Nollenkamper and Jann K. Kleffner, Internationalized Criminal Courts, Oxford (2004), ទំព័រ២១០។

៣២. ការបកស្រាយត្រង់ នៃចំណងជើងកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀងនេះបាន បង្ហាញថា មានតែ*ច្បាប់*កម្ពុជាតែ*ប៉ុណ្ណោះ* ដែលត្រូវយកមកអនុវត្ត។ ហេតុនេះ តាមពិតទៅ វិធានផ្ទៃក្នុងមិនមែនជាច្បាប់កម្ពុជា ក្នុងន័យថាបុគ្គលិកអន្តរជាតិដែលមិនមែនជាជនជាតិ កម្ពុជាបានបោះឆ្នោតអនុម័តការប្រើប្រាស់វិធានទាំងនេះ ហើយសំខាន់ជាងនេះទៀត វិធាន ទាំងនេះមិនត្រូវបានអនុម័តឲ្យប្រើ ដោយស្ថាប័នមានសិទ្ធិអំណាចតាមរដ្ឋធម្មនុញ្ញដែរ។ ដូច្នេះ មានន័យថា វិធានទាំងនេះមិនអាចចាត់ទុកថាជា "ច្បាប់(នីតិវិធី)កម្ពុជាបានទេ"។

៣៣. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បាននិយាយយោងដល់ពាក្យ ថា "នីតិវិធីដែលមានស្រាប់" ។ បើសន្មត់ថាវិធានផ្ទៃក្នុងមានសុពលភាព និងបង្កើតបានជា ផ្នែកមួយនៃ"នីតិវិធីដែលមានស្រាប់" នោះតាមស្មារតីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា មានន័យថាវិធានផ្ទៃក្នុង គឺជាផ្នែកមួយរបស់ច្បាប់នេះ។ ដូច្នេះ វិធានផ្ទៃក្នុងអាចយកមកអនុវត្តដំណាលគ្នានឹងក្រមនីតិវិធីព្រហ្មទណ្ឌ។

៣៤. បើទោះបីជាយ៉ាងនេះក្តី តាមគោលបំណងរបស់កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងឋានានុក្រមនៃលិខិតតុបករណ៍ទាំងនេះ ដែល ការពិត ច្បាប់គ្រាន់តែឆ្លុះបញ្ចាំងតាមស្មារតីកិច្ចព្រមព្រៀងប៉ុណ្ណោះ សហមេធាវីដើម បណ្តឹងរដ្ឋប្បវេណីសូមស្នើថា អ្នកធ្វើសេចក្តីព្រៀងកិច្ចព្រមព្រៀងនេះ ពិតជាមានចេតនាយក ច្បាប់(នីតិវិធី) កម្ពុជាមកអនុវត្តមែន។ គឺបញ្ហានេះហើយដែលនាំឲ្យមានការខ្វែងគំនិតគ្នាច្រើន ក្នុងដំណើរការចចារជាច្រើនឆ្នាំ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា។ ដោយសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃតុលាការ ក្នុងស្រុក ដូច្នេះជាគោលការណ៍ច្បាប់នីតិវិធីកម្ពុជា ដែលមានស្រាប់ត្រូវយកមកអនុវត្ត[22]។

៣៥. ទទ្បីករណ៍ពីខាងដើម និងការចាប់ផ្តើមបង្កើតវិធានផ្ទៃក្នុងបង្ហាញឲ្យឃើញថា ( បើទោះបីជា មានសុពលភាព) វិធានផ្ទៃក្នុង មានឋានានុក្រមទាបជាងក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ។

---

[22] សូមមើល កំណត់ចំណងជើង ១៦។

វិធានផ្ទៃក្នុង ស្រដៀងគ្នាទៅនឹងអនុក្រឹត្យ ឬប្បញ្ញត្តិលក្ខខន្តិកៈ ហេតុដូច្នេះទើបមានឋានានុក្រមទាបជាងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងឋានានុក្រមនៃបទប្បញ្ញត្តិ។

៣៥. ឋានានុក្រមនៃប្បញ្ញត្តិនៅកម្ពុជាមានដូចខាងក្រោម[23]:

- រដ្ឋធម្មនុញ្ញ
- ច្បាប់ អនុម័តដោយសភាជាតិ
- អនុក្រិត្យ សរាចរណ៍ណែនាំ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី
- ប្រកាស ចេញដោយរដ្ឋមន្ត្រី

៣៦. មកទល់ពេលនេះ ទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ មិនទាន់ត្រូវបានគេវែកញែកនៅឡើយ ក៏ប៉ុន្តែអ្នកសិក្សាស្រាវជ្រាវបានចាត់ទុកថាវាមានលក្ខណៈ "ជាទីចាប់អារម្មណ៍ក្នុងការស្វែងយល់ថាតើ ទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ជាធរមាន" នឹងដំណើរការទៅយ៉ាងដូចម្តេច"[24]។

ទោះបីជាយ៉ាងនេះក្តី ការបកស្រាយមានលក្ខណៈសាមញ្ញទៅលើកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងគោលបំណងនៃលិខិតតុបករណ៍ទាំងពីរ មានន័យថាវិធានផ្ទៃក្នុងមានឋានានុក្រមទាបជាងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយគោលការណ៍ទូទៅដែល ច្បាប់ធំ សំខាន់ជាងច្បាប់តូច (lex superior derogate legi inferiori) ត្រូវយកមកអនុវត្ត[25]។

---

[23] សូមមើល Council of Jurists, http://www.bigpond.com.kh/Council_of_Jurists/z/Typolg.htm. (បានមើលនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨)។

[24] សូមមើល កំណត់ចំណាំងជើង ១៦។

[25] E. Vranes, Lex Superior, Lex Specialis, Lex Posterior- Zur Rechtsnatur der "Konfliktlösungsregeln", ZaoeRV(2005), p. 397,398 " …so erscheinen die Sätze vom Vorrang der lex superior, lex posterior bzw. lex specialis in der Tat als bloße, aber notwendige Schlussfolgerungen, die sich aus der Struktur der Rechtsordnung ergeben: Soweit es in der Rechtsordnung höherrangiges und niederrangiges Recht gibt, muss die lex inferior im Grundsatz der lex superior weichen, wenn nicht die Struktur der Rechtsordnung ad absurdum geführt werden soll."
Unauthorized translation: The primacy of l*ex superior, lex posterior* or *lex specialis* seems to stem from the simple but necessary conclusion inherent in a legal system: where superior and inferior law exist within the

គោលការណ៍ ច្បាប់ពិសេស សំខាន់ជាងច្បាប់ទូទៅ (lex specialis derogate legi generadi) ត្រូវយកមកអនុវត្តចំពោះតែច្បាប់ ណាដែលមានឋានានុក្រមដូចគ្នាប៉ុណ្ណោះ។ ក្នុងស្មារតីនេះហើយ ទើបបុព្វកថានៃវិធានផ្ទៃក្នុង បានចែងថាវិធានទាំងនេះច្របាច់បញ្ចូល ច្បាប់នីតិវិធីកម្ពុជា ដែលយកមកអនុវត្តបានចំពោះកិច្ចដំណើរការក្តីនេះ។ វិធានផ្ទៃក្នុង ដែលបានអនុម័តរួចហើយចែងថា "នៅពេលណាច្បាប់កម្ពុជាជាធរមានពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តន៍ ឬក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ"។

៣៧. ដូច្នេះ បុព្វកថាបានទទួលស្គាល់លក្ខណៈទាបជាងនៃវិធានផ្ទៃក្នុង ក្នុងការបំពេញនូវចន្លោះខ្វះខាត ភាពមិនច្បាស់លាស់ ឬបញ្ហាចោទនៃភាពមិនសបស្រាបគ្នានឹងនិយាមអន្តរជាតិ ហើយវិធានផ្ទៃក្នុងគួរចូលរួមបង្គ្រប់ជាមួយក្រមនីតិវិធីព្រហ្មទណ្ឌ។

៣៨. ហេតុនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមអះអាងថាវិធានផ្ទៃក្នុងពិតជាពុំអាចបង្កើតសិទ្ធិបន្ថែម ឬកាតព្វកិច្ចបន្ថែមដល់ភាគី ឬស្ថាប័នណាមួយឡើយ ហើយវិធានផ្ទៃក្នុងនេះក៏ពុំអាចកំហិតសិទ្ធិរបស់ភាគី ដែលផ្តល់ឲ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌដែរ។

៣៩. បើពិចារណាពីដំណើរកកើតវិធានផ្ទៃក្នុងឃើញថាតាមការបកស្រាយតាមន័យត្រង់ក្តី ក៏ដូចជាការបកស្រាយតាមគតិច្បាប់ក្តីទៅលើកិច្ចព្រមព្រៀង និងច្បាប់ស្តីពី ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាំឲ្យគេអាចទាញសេចក្តីសន្និដ្ឋានជារួមមួយថា ក្នុងករណីមានការងាកចេញរបស់វិធានផ្ទៃក្នុងពីក្រមនីតិវិធីព្រហ្មទណ្ឌ ឬក្នុងករណីមានទំនាស់គតិយុត្តិរវាងច្បាប់ទាំងពីរខាងលើ នោះក្រមនីតិវិធីព្រហ្មទណ្ឌនឹងមានអាទិភាពជាងវិធានផ្ទៃក្នុង។

---

same legal system, in principle, the superior law prevails over the inferior law if the structure of the legal system is not to be reduced to absurdity.

## ឃ. ការវាយតម្លៃចុងក្រោយលើកថាខណ្ឌដែលចម្រូងចម្រាសក្នុងសេចក្ដីសម្រេចរបស់អ.ប.ជ

៤០. ការសម្រេចរបស់អ.ប.ជ ដែលថាវិធានផ្ទៃក្នុងគឺជាប្រភពចម្បងនៃនីតិវិធីរបស់អ.វ.ត.ក មិនស្របគ្នាជាមួយច្បាប់កម្ពុជាជាធរមានទេ។

ការគូសបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌអនុវត្តតែក្នុងករណីដែលវិធានផ្ទៃក្នុងមិនមានចែងនោះ គឺផ្ទុយស្រឡះពីបទប្បញ្ញត្តិជាក់ស្ដែងនៃកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក។ មិនតែប៉ុណ្ណោះ ទទ្បីករណ៍របស់អង្គបុរេជំនុំជម្រះគឺផ្ទុយទាំងស្រុងនឹងច្បាប់កម្ពុជា និងស្មារតីនៃច្បាប់នេះ ហើយក៏ផ្ទុយទៅនឹងតួនាទី និងចរិកលក្ខណៈនៃវិធានផ្ទៃក្នុង ដូចមានចែងក្នុងបុព្វកថានៃវិធានទាំងនេះផងដែរ។

ផ្ទុយពីការគូសបញ្ជាក់របស់អង្គបុរេជំនុំជម្រះ វិធានផ្ទៃក្នុងពិតជាផ្ទុយគ្នាពីក្រមនីតិវិធីព្រហ្មទណ្ឌ។ ការខុសប្លែកគ្នានេះមានបង្ហាញក្នុងឧទាហរណ៍ជាច្រើនខាងលើ។[26]

ម្យ៉ាងវិញទៀត ការអះអាងដ៏មានមន្ទិលរបស់អង្គបុរេជំនុំជម្រះនេះ មិនមានសម្អាងផ្លូវច្បាប់ ឬឯកសារយោងដើម្បីគាំទ្រដែរ។

៤១. អង្គបុរេជំនុំជម្រះមានអំណាចបកស្រាយច្បាប់ ប៉ុន្តែអំណាចនេះត្រូវឋិតនៅក្រោមច្បាប់។ អង្គបុរេជំនុំជម្រះមិនមានសិទ្ធិអំណាច "ប្រកាស"ថា វិធានផ្ទៃក្នុងមានលក្ខណៈគ្រប់គ្រាន់ដោយខ្លួនឯង ហើយយកវិធានទាំងនេះជាវិធានគោលនៃច្បាប់នីតិវិធីជាធរមាននោះទេ។

៤២. គេប្រាកដជាសន្និដ្ឋានថាជំហររបស់អង្គបុរេជំនុំជម្រះមិនអនុលោមទៅតាមច្បាប់ ហើយក៏មិនមានអ្វីជាទីសម្អាងដែរ។

## ឃ. អត្ថិភាពនៃបុរេវិនិច្ឆ័យសម្រាប់ការទទួលយកសំណើសុំការពិចារណាឡើងវិញ

៤៣. តាមបុរេវិនិច្ឆ័យខាងលើ[27] សម្រាប់ទទួលយកសំណើសុំការពិចារណាឡើងវិញនេះ សេចក្ដី

---

[26] សូមមើលកថាខណ្ឌ ១២ នៃសារណានេះ

[27] សូមមើលកថាខណ្ឌ ៩ នៃសារណានេះ

សម្រេចក្នុងករណីនេះគួរត្រូវបានពិនិត្យពិចារណាឡើងវិញ ដោយឈរលើមូលដ្ឋានពីរ៖

(១) សេចក្តីសម្រេចពីមុនមានការភ័នច្រឡំ និង

(២) សេចក្តីសម្រេចពីមុននាំឲ្យមានភាពអយុត្តិធម៌

៤៤. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា ការសម្រេចរបស់អង្គបុរេជំនុំជម្រះមិនអនុលោមតាមស្មារតីនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ ឬរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ ហេតុដូចនេះ នេះគឺជាសេចកីសម្រេចមួយ ដែលមានការភ័នច្រឡំ ដូច្នេះសេចក្តីសម្រេចនេះអាចត្រូវទទួលយកទៅពិចារណាឡើងវិញ។

៤៥. លើសពីនេះទៅទៀត ការអះអាងរបស់អង្គបុរេជំនុំជម្រះស្តីអំពីទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនាំឲ្យមានភាពអយុត្តិធម៌ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះតាមសេចក្តីអះអាងនេះ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់ឲ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានគេបង្រួមដោយខុសច្បាប់។

**ដោយសារហេតុផលដូចដែលបានលើកឡើងខាងលើនេះ**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំទៅអង្គបុរេជំនុំជម្រះមេត្តា**

(១) ពិចារណាឡើងវិញនូវការសម្រេចរបស់អង្គបុរេ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ និង

(២) ក្នុងករណីដែលវិធានផ្ទៃក្នុងនៅតែមានសុពលភាព សូមអង្គបុរេជំនុំជម្រះសម្រេចទៅតាមបទប្បញ្ញត្តិនៃច្បាប់ដែលពាក់ព័ន្ធ ដែលក្នុងនោះក្រមនីតិវិធីព្រហ្មទណ្ឌមានអទិភាពជាងវិធានផ្ទៃក្នុង ក្នុងករណីដែលលិខិតតុបករណ៍ទាំងពីរនេះមានភាពមិនស្របគ្នា ឬខុសគ្នា។

សូមដាក់សំណើជូនដោយសេចក្តីគោរពពី

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី ហុង គីមសួន

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

មេធាវី ឡោ ជុនធី

អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

មេធាវី នី ចាន់ឌី

អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

មេធាវី គង់ ពិសី

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

មេធាវី យុង ផានិត

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

Silke Studzinsky

មេធាវី Silke Studzinsky

មេធាវីអន្តរជាតិ

មេធាវី គីម ម៉េងឃី

មេធាវីឥតព្រំដែន

មេធាវី Martine Jacquin

មេធាវីអន្តរជាតិ

មេធាវី Philippe Cannone

មេធាវីអន្តរជាតិ

បានចុះហត្ថលេខា ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨

ភ្នំពេញ